ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

ឆ្នាំទី ៧ លេខ ១៤ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

[illegible]

* * * * *

២៥៦១ ខែ មេសា ទី ៥១ ឆ្នាំ ៦១ លេខ ៣ [illegible]

# មាតិកា

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ៩-៤-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨០ តែងតាំងស្តេចក្រុមឃុន នរោត្តម ចក្រពង្ស ជាឧត្តមប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រ | ៦៦៧ |
| ១០-៤-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨១ តែងតាំងឥស្សរជន ចំនួន០៣ រូប ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី | ៦៦៨ |
| ១០-៤-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨២ តែងតាំងឥស្សរជន ចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី | ៦៦៩ |
| ១០-៤-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨៣ តែងតាំងឯកឧត្តម អ៊ុំ មាន ជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | ៦៧០ |
| ១១-៤-១៩៩៩ | -ព្រះរាជក្រឹត្យនស/រកត/០៤៩៩/៨៤ លើកលែងទោសឲ្យទណ្ឌិត ចៅ សុខុន | ៦៧០ |
| ១៣-៤-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨៥ តែងតាំងឯកឧត្តម ថម ប៊ែល (TO M BELL ) ជាទីប្រឹក្សាប្រធានរដ្ឋសភា | ៦៧១ |
| ១៤-៤-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨៦ តែងតាំងលោក ញ៉ែម កុសល ជាឧកញ៉ា | ៦៧២ |
| ១៤-៤-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨៧ តែងតាំងលោក សុះគីរ៉ុ ជាឧកញ៉ា | ៦៧៣ |


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ៩-៤-១៩៩៩ | -អនុក្រឹត្យលេខ ២៨ អនក្រ.បក ស្តីពីការបន្ថែមប្រាក់បៀវត្ស ជូនមន្ត្រីរាជការស៊ីវិល យោធានគរបាលជាតិ និវត្តជន និង មន្ត្រីបាត់បង់សមត្ថភាពពលកម្ម | ៦៧៣ |
| ១២-៤-១៩៩៩ | -អនុក្រឹត្យលេខ ២៩ អនក្រ.បក ស្តីពីការកំណត់សមត្ថកិច្ចរបស់ខេត្ត ក្រុង | ៦៧៥ |
| ១២-៤-១៩៩៩ | -អនុក្រឹត្យលេខ ៣០ អនក្រ.បក ស្តីពីរបបរដ្ឋបាលហិរញ្ញវត្ថុ និងការប្រព្រឹត្តទៅ នៃរដ្ឋាកររបស់ ខេត្ត ក្រុង | ៦៧៧ |
| ១៣-៤-១៩៩៩ | -អនុក្រឹត្យលេខ ៣១ អនក្រ.បក ស្តីពីការ ផ្ទេរឥណទាន | ៦៨២ |
| ១៣-៤-១៩៩៩ | -អនុក្រឹត្យលេខ ៣២ អនក្រ.បក ស្តីពីការ បង្កើតស្ថានអគ្គកុងស៊ុល | ៦៨៣ |

| | | |
|---|---|---|
| ១៣-៤-១៩៩៩ | -អនុក្រឹត្យលេខ ៣៣ អនក្រ.បក ស្តីពីការ បង្កើតស្ថានអគ្គកុងស៊ុល | ៦៨៤ |
| ៩-៤-១៩៩៩ | -អនុក្រឹត្យលេខ ១០០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៦៨៥ |
| ៩-៤-១៩៩៩ | -អនុក្រឹត្យលេខ ១០១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៦៨៦ |
| ៩-៤-១៩៩៩ | -អនុក្រឹត្យលេខ ១០២ អនក្រ.តត ស្តីពីការតែងតាំង ក្រុមប្រឹក្សាភិបាលអាជ្ញាធរអប្សរា | ៦៨៧ |
| ១២-៤-១៩៩៩ | -អនុក្រឹត្យលេខ ១០៣ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចរបស់មន្ត្រីរាជការ | ៦៨៨ |
| ១២-៤-១៩៩៩ | -អនុក្រឹត្យលេខ ១០៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៦៨៩ |
| ១២-៤-១៩៩៩ | -អនុក្រឹត្យលេខ ១០៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៦៩០ |
| ១២-៤-១៩៩៩ | -អនុក្រឹត្យលេខ ១០៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៦៩១ |
| ១២-៤-១៩៩៩ | -អនុក្រឹត្យលេខ ១០៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៦៩១ |
| ១៣-៤-១៩៩៩ | -អនុក្រឹត្យលេខ ១០៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៦៩២ |
| ១៣-៤-១៩៩៩ | -អនុក្រឹត្យលេខ ១០៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៦៩៣ |
| ១៣-៤-១៩៩៩ | -អនុក្រឹត្យលេខ ១១០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៦៩៤ |
| ១៣-៤-១៩៩៩ | -អនុក្រឹត្យលេខ ១១១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៦៩៤ |


## ២-សេចក្តីសំរេច


| | | |
|---|---|---|
| ៩-៤-១៩៩៩ | -សេចក្តីសំរេចលេខ ៣៣ សសរ ស្តីពីការបង្កើតគណៈកម្មការវេចខ្ចប់ និងដឹកជញ្ជូនសំណល់ផ្លាស្ទិកចំនួន៦៥០ តោន ចេញពីព្រះរាជាណាចក្រកម្ពុជា | ៦៩៥ |
| ៩-៤-១៩៩៩ | -សេចក្តីសំរេចលេខ ៣៤ សសរ ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យវាយតំលៃសិក្ខាបទសញ្ញាប័ត្រ និងបើកពិធីបញ្ចប់ការសិក្សា | ៦៩៦ |
| ៩-៤-១៩៩៩ | -សេចក្តីសំរេចលេខ ៣៥ សសរ ស្តីពីការបង្កើតគណៈកម្មការរៀបចំពិធីសម្ពោធ និង ដាក់អោយដំណើរការជាផ្លូវការ ខេត្តឧត្តរមានជ័យ | ៦៩៨ |
| ១២-៤-១៩៩៩ | -សេចក្តីសំរេចលេខ ៣៦ សសរ ស្តីពីការបង្កើតគណៈកម្មការ សំរាប់ដោះស្រាយ បញ្ហាដីធ្លី នៅខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ និង ខេត្ត តាកែវ | ៦៩៩ |
| ១២-៤-១៩៩៩ | -សេចក្តីសំរេចលេខ ៣៧ សសរ ស្តីពីការបង្កើតគណៈកម្មការដោះស្រាយទីតាំង និង ជួសជុលបូរីកីឡា | ៧០១ |


## ៣-សារាចរណែនាំ


| | | |
|---|---|---|
| ៩-៤-១៩៩៩ | -សារាចរណែនាំលេខ ០៦ សរ.ណន ស្តីពីការធានានិរន្តរភាព សកម្មភាពអាហារ័ណ នីហរ័ណ ទំនិញ នៅថ្ងៃឈប់សំរាកការងារ | ៧០៣ |

# III- ការងារបណ្ណាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ប្រកាស


| | | |
|---|---|---|
| ១២-៤-១៩៩៩ | -ប្រកាសលេខ ៤០២ ផក.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុន អលឡាយ ស្មាត ថិចថាយ ខូអិុលធីឌី តំណាងដោយលោក NGAN SHUN KWING BEN សញ្ជាតិ កាណាដា បង្កើតរោងចក្រកាត់ដេរ អលឡាយ ស្មាត ថិចថាយ | ៧០៤ |
| ១៥-៤-១៩៩៩ | -ប្រកាសលេខ ៤០៣ ផក.ប្រក អនុញ្ញាតិឲ្យក្រុមហ៊ុន វែលឌិង លីមីធីត តំណាងដោយលោក IANENKO GUEORGUI សញ្ជាតិ រុស្ស៊ី បង្កើតរោងចក្រផលិតធូបផ្សារ | ៧០៥ |
| ១៥-៤-១៩៩៩ | -ប្រកាសលេខ ៤០៤ ផក.ប្រក អនុញ្ញាតិឲ្យក្រុមហ៊ុន ខេមបូឌា ហ្វេសិន ខូអិុលធីឌី តំណាងដោយលោក NGAN SHUN KWING BEN សញ្ជាតិ កាណាដា បង្កើតរោងចក្រកាត់ដេរ ខេមបូឌា ហ្វេសិន | ៧០៧ |

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជបរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

តែងតាំង

ស្តេចក្រុមឃុន នរោត្តម ចក្រពង្ស

ជា

ឧត្តមប្រឹក្សាផ្ទាល់ របស់ព្រះមហាក្សត្រ

នៃព្រះរាជាណាចក្រកម្ពុជា

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

***

ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីស្នើសុំរបស់ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ .**_ តែងតាំង **ឥស្សរជន** ចំនួន ០៣ រូប ជា **ទីប្រឹក្សា** ផ្ទាល់របស់ ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដែលមានឈ្មោះដូចតទៅ ៖

១- ឯកឧត្តម អ៊ុយ ស៊ឹម

២- ឯកឧត្តម ចៅ វណ្ណលី

៣- ឯកឧត្តម ឃាវ៉ាណ ស៊ីវល័យ

**មាត្រា ២ .**_ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ .**_ ព្រះរាជក្រឹត្យនេះចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១០ ខែមេសា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

***

# ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីស្នើសុំរបស់ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ .**_ តែងតាំង ឥស្សរជន ចំនួន ០៣ រូប ជា **ទីប្រឹក្សា** ផ្ទាល់របស់ ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយមានឋានៈស្មើ **អគ្គនាយក** ដែលមានឈ្មោះដូចត ទៅ ៖

៤- ឯកឧត្តម **មាស សារឹម**

៥- ឯកឧត្តម **ខៀវ សុគន្ធ**

៦- លោកជំទាវ **គឹម សត្ថាវី**

**មាត្រា ២ .**_ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ .**_ ព្រះរាជក្រឹត្យនេះចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១០ ខែមេសា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

## ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើរបស់ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១ ._** តែងតាំងលោកឧត្តម អ៊ឹ មាន ជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ។

**មាត្រា ២ ._** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ ._** ព្រះរាជក្រឹត្យនេះចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១០ ខែមេសា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

☆☆★

## ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់មាត្រា ២៧ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩៩

**ត្រាស់បង្គាប់**

មាត្រា ១ ._ ត្រូវបើកលែងទោសអោយទណ្ឌិត **ចៅ សុខុន** ចំពោះទោសជាប់ពន្ធនាគារ នឹងប្រាក់ពិន័យដែលត្រូវបានតុលាការក្រុងភ្នំពេញ ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៥ " ក" ចុះថ្ងៃទី២៧-៦-៩៧ នឹងផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២០ " ក " ចុះថ្ងៃទី ១-៩-៩៧ ។

មាត្រា ២ ._ ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៣ ._ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ នឹងក្រសួងមហាផ្ទៃ ត្រូវការអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេចជាស្ថាពរ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១១ ខែមេសា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨៥**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមសំណើរបស់សម្តេចក្រុមព្រះ **នរោត្តម រណឬទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

**ត្រាស់បង្គាប់**

មាត្រា ១ ._ តែងតាំង ឯកឧត្តម **ថម ប៊ែល** ( TOM BELL ) ជាទីប្រឹក្សាប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា ២ ._ អគ្គលេខាធិការដ្ឋានរដ្ឋសភា ខុទ្ទកាល័យផ្ទាល់ប្រធានរដ្ឋសភា រាជរដ្ឋាភិបាល និងសាមីខ្លួនត្រូវអនុវត្តអោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែមេសា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

***

# ព្រះរាជក្រឹត្យ

## ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

## តែងតាំង

## លោក យ៉ែម កុសល

## ជា

## ឧកញ៉ា

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

***

ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨៧

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

***

តែងតាំង

លោក សុះ គីរី

ជា

ឧកញ៉ា

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ២៨ អនក្រ.បក

### ស្តីពីការបន្ថែមប្រាក់បៀវត្ស ជូនមន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ និវត្តជន និង មន្ត្រីបាត់បង់សមត្ថភាពពលកម្ម

★★★

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- យោងការសំរេចរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី០២ ខែមេសា ឆ្នាំ ១៩៩៩

**សំរេច**

មាត្រា ១ ._ ត្រូវបានអនុញ្ញាតអោយបន្ថែមប្រាក់បៀវត្ស ចំនួន ៣០ ភាគរយ លើបៀវត្សគោលសុទ្ធសាធ ជូនមន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ និវត្តជន និង មន្ត្រីបាត់បង់សមត្ថភាពពលកម្ម ។

មាត្រា ២ ._ ប្រាក់បៀវត្សដែលបន្ថែម ៣០ ភាគរយនេះ ត្រូវចាប់អនុវត្ត ពីខែ ឧសភា ឆ្នាំ ១៩៩៩ តទៅ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**បានជំរាបជូន**

សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

***

## អនុក្រឹត្យលេខ ២៩ អនក្រ.បក

## ស្តីពីការកំណត់សមត្ថកិច្ចរបស់ខេត្ត ក្រុង

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- យោងតាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ ._** ដោយអនុលោមទៅតាមមាត្រា ៥ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ខេត្ត ក្រុងជាអ្នកទទួលបន្ទុកគ្រប់គ្រងកិច្ចការផលប្រយោជន៍ ក្នុងមណ្ឌលដែនដីរបស់ខ្លួន ដើម្បីធានាអោយសេវាសាធារណៈ ដែលមិនស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់រដ្ឋ ឆ្លើយតបទៅនឹងតំរូវការរបស់ប្រជាពលរដ្ឋក្នុងខេត្ត ក្រុង ។

**មាត្រា ២ ._** នៅក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិនៃមាត្រា ១ ខាងលើនេះ ត្រូវបានប្រគល់អោយខេត្ត ក្រុង នូវសមត្ថកិច្ចនានា ដែលមានជាអាទិ៍ដូចខាងក្រោមនេះ ៖

**១-សមត្ថកិច្ចស្តីពីការរៀបចំផែនការ និង កម្មវិធីអភិវឌ្ឍន៍ :**

- រៀបចំផែនការអភិវឌ្ឍន៍ខេត្ត ក្រុង ដោយធ្វើសមាហរណកម្ម ទៅក្នុងក្របខ័ណ្ឌនៃផែនការរដ្ឋសំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ។
- ពិនិត្យរួមយោបល់ ទៅលើកម្មវិធី និងគំរោងនានាដែលរដ្ឋមានគោលបំណងធ្វើនៅខេត្ត ក្រុង
- រៀបចំកម្មវិធីអភិវឌ្ឍន៍ខេត្ត ក្រុងកំណត់នូវលក្ខខណ្ឌនៃហិរញ្ញប្បទាន និងអនុវត្តកម្មវិធីទាំងនោះ ។
- សំរបសំរួលកម្មវិធីរបស់ខេត្ត ក្រុង ជាមួយនឹងកម្មវិធីជាតិ ដែលមានការទាក់ទងដល់ខេត្ត ក្រុង

**២-សមត្ថកិច្ចស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ :**

- រៀបចំគូសប្លង់គោលស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ អោយស្របតាម ស្ថានភាពពិសេស នៃខេត្ត ក្រុងនិមួយៗ ក្នុងស្មារតីការពារដល់បេតិកភ័ណ្ឌ ដល់បរិស្ថាន ការពារធនធានធម្មជាតិ និងធានាដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ។
- ផ្អែកតាមប្លង់គោលខាងលើ ត្រូវរៀបចំប្លង់ស្តីពីការប្រើប្រាស់ដីធ្លី និង សំណង់សំរាប់ខេត្ត ក្រុង ដោយបញ្ជាក់អោយច្បាស់អំពីតំបន់សំរាប់កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម វប្បធម៌ ទេសចរណ៍ សាសនា លំនៅស្ថាន រដ្ឋបាល និង ទីធ្លាសាធារណៈ ។

- អនុញ្ញាតអោយកាន់កាប់នូវទ្រព្យសម្បត្តិដែលរដ្ឋផ្តល់អោយ ឬ ជាកម្មសិទ្ធិរបស់ខេត្ត ក្រុង ដោយទទួលបាននូវផលទុនពីទ្រព្យសម្បត្តិទាំងនោះ ក្នុងក្របខ័ណ្ឌនៃការប្រើប្រាស់ និង ពេលវេលាដែលត្រូវកំណត់ដោយគណៈកម្មការរបស់អភិបាលខេត្ត ក្រុង ។
- ផ្តល់លិខិតអនុញ្ញាតឯកត្តជននៃការរៀបជាផ្ទះ និង លិខិតអនុញ្ញាតផ្សេងៗទៀតពាក់ព័ន្ធទៅនឹងផ្លូវថ្នល់ ជាទ្រព្យសម្បត្តិដែលរដ្ឋប្រគល់អោយ ឬ ជាកម្មសិទ្ធិរបស់ខេត្ត ក្រុង ។
- អនុញ្ញាតអោយកាន់កាប់ដីឡូត៍ សាងសង់ កែលំអ ជួសជុល រុះរើសំណង់ដែលស្ថិតនៅក្នុងដែនដីរបស់ ខេត្ត ក្រុង ។
- ពិនិត្យ និង ចាត់វិធានការតាមផ្លូវច្បាប់និងបទបញ្ញាជាធរមាន នូវបទល្មើសនៃការសាងសង់ការរៀបជាផ្ទះ ការពង្រាបផ្លូវថ្នល់ព្រមទាំងរាល់បទល្មើសទៅនឹងបទបញ្ញត្តិច្បាប់ និងបទបញ្ញាដែលទាក់ទងដល់ការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ។

៣-សមត្ថកិច្ចស្តីពីការងារសាធារណការ :

- កសាង ជួសជុល ថែទាំផ្លូវគមនាគមន៍នៅជនបទ និងផ្លូវគមនាគមន៍ដែលរដ្ឋប្រគល់អោយខេត្ត ក្រុង គ្រប់គ្រង ។
- កសាង ជួសជុល ថែទាំផ្លូវនិងប្រឡាយទឹកសំរាប់វិស័យកសិកម្ម ។

៤-សមត្ថកិច្ចស្តីពីសេវាសាធារណៈ :

- រៀបចំបំភ្លឺទីសាធារណៈ និង ការផ្គត់ផ្គង់ទឹកស្អាត
- រៀបចំសណ្តាប់ធ្នាប់ចរាចរ និង ការដឹកជញ្ជូននៅក្នុងទីក្រុង និងក្នុងទីប្រជុំជននានា ។
- ចាត់វិធានការបង្ការ និងពន្លត់អគ្គិភ័យ
- រៀបចំការងារសុខាភិបាល និងអនាម័យដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ខេត្ត ក្រុង ។
- រៀបចំអោយមានអនាម័យ សុខភាព ការបោសសំអាត ការប្រមូលសំរាម និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងខេត្ត ក្រុង ។
- គ្រប់គ្រងទីផ្សារ និង សត្តឃាតដ្ឋាន ។
- រៀបចំកីឡាកីឡា និង វប្បធម៌ ។
- រៀបចំសួនច្បារ និង ឧទ្យាន ។
- សង្គ្រោះចំពោះជនទីទ័លក្រ ជនអនាថា ។
- រៀបចំ និងគ្រប់គ្រងតំបន់ ដែលរដ្ឋផ្តល់អោយខេត្ត-ក្រុង ។

**មាត្រា ៣ .**_ អភិបាលខេត្ត ក្រុង ត្រូវរៀបចំនូវដីការ និង លិខិតបទដ្ឋាននានា ដើម្បីដាក់ចេញនូវវិធានការអនុវត្តជាក់ស្តែង នូវសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ២ ខាងលើនេះ ដោយផ្អែកលើមូលដ្ឋាន នៃបទបញ្ញត្តិទាំងឡាយនៃច្បាប់ លិខិតបទដ្ឋានតាមផ្លូវច្បាប់ និង គោលនយោបាយរបស់រដ្ឋ ។

**មាត្រា ៤ .**_ ក្នុងករណីពិនិត្យឃើញថា លិខិតបទដ្ឋាន ឬសកម្មភាពណាមួយរបស់ខេត្ត ក្រុងធ្វើឡើងផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានតាមផ្លូវច្បាប់ និង គោលនយោបាយរបស់រដ្ឋ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញ

ប្រកាសលុបចោលលិខិត លិខិតបទដ្ឋាន ឬ បញ្ញប់សកម្មភាពនោះជាបន្ទាន់ ហើយចាត់វិធានការណែនាំអោយបានត្រឹមត្រូវឡើងវិញ ។

មាត្រា ៥ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត ក្រុងត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែមេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
គាត ឈន់

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
ដើម្បីចុះហត្ថលេខា
សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ស ខេង យូហុកគ្រី

★★★

## អនុក្រឹត្យលេខ ៣០ អនក្រ.បក

## ស្តីពីរបបរដ្ឋបាល ហិរញ្ញវត្ថុ និង ការប្រព្រឹត្តិទៅនៃរដ្ឋាករបស់ខេត្ត ក្រុង

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- យោងតាមសំណើរបស់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ជំពូកទី ១
## បទបញ្ញត្តិទូទៅ
## សំរេច

**មាត្រា ១ .-** អនុលោមទៅតាមមាត្រា ២៥ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ការធ្វើអាជីវកម្មផ្ទាល់នៃសេវាសាធារណៈរបស់ខេត្ត ក្រុង ក្រោមរូបភាពជារដ្ឋាករ ត្រូវស្នើឡើងដោយអភិបាល ខេត្ត ក្រុង ។ ការស្នើនេះត្រូវស្ថិតនៅក្រោមការអនុញ្ញាតរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ការអនុញ្ញាត ឬ ការដកហូតការអនុញ្ញាត ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២ .-** ក្នុងករណីរដ្ឋាករមិនទាន់មានថវិកាស្វយ័ត ចំណូល និង ចំណាយរបស់រដ្ឋាករ ត្រូវកត់ត្រានៅក្នុងថវិការបស់ខេត្ត ក្រុង ។ គណនេយ្យកររបស់ខេត្ត ក្រុង ត្រូវចុះកិច្ចបញ្ជីការគណនេយ្យនូវចំណូល និងចំណាយរបស់រដ្ឋាករ ដោយអនុលោមទៅតាមបទបញ្ញាជាធរមាន នៅក្នុងគណនេយ្យរបស់ខេត្ត ក្រុង ។

**មាត្រា ៣ .-** ក្នុងករណីសេវាសាធារណៈរបស់ខេត្ត ក្រុង ត្រូវបានអនុញ្ញាតអោយធ្វើអាជីវកម្មជារដ្ឋាករមានថវិកាស្វយ័តនោះ របបរដ្ឋបាលនិងហិរញ្ញវត្ថុ និងការប្រព្រឹត្តិទៅនៃរដ្ឋាករស្វយ័តទាំងនោះ ត្រូវគោរពទៅតាមបទបញ្ញត្តិនានានៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## របបរដ្ឋបាលនៃរដ្ឋាកររបស់ខេត្ត ក្រុង

**មាត្រា ៤ .-** រដ្ឋាកររបស់ខេត្ត ក្រុង ត្រូវគ្រប់គ្រងដោយគណកម្មាធិការអាជីវកម្មមួយ ដែលដឹកនាំអភិបាលខេត្ត ក្រុង ឬ អភិបាលរងម្នាក់ និង មានសមាសភាពដទៃទៀតដូចតទៅ ៖

- អភិបាលរដ្ឋាករម្នាក់ ជួយអភិបាលខេត្ត ក្រុង ក្នុងការគ្រប់គ្រងរដ្ឋាករ ហើយអភិបាលរដ្ឋាករនេះត្រូវបានតែងតាំងដោយអភិបាលខេត្ត ក្រុង ក្នុងចំណោមភ្នាក់ងាររបស់ខេត្ត ក្រុង ។
- មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរបស់ខេត្ត ក្រុង
- ប្រធានការិយាល័យខេត្ត ក្រុងម្នាក់ ឬ ច្រើននាក់ នៃផ្នែកដែលមានទំនាក់ទំនងការងារជាមួយរដ្ឋាករ ។
- ប្រជាពលរដ្ឋពីរនាក់ ដែលជ្រើសរើសដោយអភិបាលខេត្ត ក្រុង ពីចំណោមអ្នកប្រើប្រាស់ដែលជានីតិជន មានភាពស្មោះត្រង់ត្រឹមត្រូវ និង ជាប្រជាពលរដ្ឋល្អ ដឹងខុសដឹងត្រូវ ។
- សមាជិកនៃគណៈកម្មាធិការអាជីវកម្ម ត្រូវបានចាត់តាំងដោយដីការបស់ខេត្ត ក្រុង។សមាជិកនៃគណៈកម្មាធិការអាជីវកម្មមិនអាចជាសហគ្រិន ឬ ជាអ្នកផ្គត់ផ្គង់នៃសេវាណាមួយ ឬចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនណាមួយ ដែលមានទំនាក់ទំនងការងារជាមួយរដ្ឋាករឡើយ ។

អ្នកដែលប្រព្រឹត្តល្មើសនិងបទបញ្ញត្តិទាំងនេះ ត្រូវបានប្រកាសអោយបោះបង់ពីតំណែងគណៈកម្មាធិការអាជីវកម្ម ដោយអភិបាលខេត្ត-ក្រុង ។

មាត្រា ៥ .- គណៈកម្មាធិការអាជីវកម្ម ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់អភិបាលខេត្ត ក្រុង ឬ អភិបាលរងតាមការចាំបាច់ យ៉ាងតិចមួយដងក្នុងរយៈពេលពីរខែ និង ត្រូវមានកំណត់ហេតុរបស់លើក នៃការប្រជុំនេះ ។

គណៈកម្មាធិការអាជីវកម្មនេះ ត្រូវពិគ្រោះយោបល់គ្នាតែទៅលើប្រភេទកិច្ចការណាដែលស្ថិតនៅក្នុងសកម្មភាពរបស់រដ្ឋាករ ដែលមានជាអាទិ៍ដូចតទៅ ៖

- ទាយជ្ជទានដំបូងដែលខេត្ត ក្រុង ផ្តល់សំរាប់ការរៀបចំរដ្ឋាករ និង ការកែប្រែជាយថាហេតុដែលកើតមានចំពោះទាយជ្ជទាននេះ ។
- តារាងតំលៃវត្ថុផ្គត់ផ្គង់ កាលណាតារាងតំលៃទាំងនេះ មិនត្រូវបានកំណត់ដោយច្បាប់ និងបទបញ្ញាជាធរមានទេ ។
- ថវិកា និង គណនីរបស់រដ្ឋាករ ។
- លទ្ធកម្មកិច្ចសន្យា កិច្ចសន្យាជួល ពាណិជ្ជកម្ម និង បណ្តឹងជាយថាហេតុ ។
- វិធានការដែលត្រូវរៀបចំនៅក្នុងពេលកំពុងអនុវត្ត ឬ នៅដំណាច់ឆ្នាំ បន្ទាប់ពីមានលទ្ធផលនៃអាជីវកម្មរបស់រដ្ឋាករ ។ វិធានការទាំងនេះ អាចអនុវត្តបានបន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ៦ .- អភិបាលនៃរដ្ឋាករ ត្រូវធានាអោយការប្រព្រឹត្តិទៅរបស់រដ្ឋាករមានដំណើរការល្អ និង ទទួលបន្ទុកជាអាទិ៍ ៖

- រៀបចំការងាររបស់គណៈកម្មាធិការអាជីវកម្ម និង ទទួលភារៈបំពេញមុខងារជាលេខាធិការនៃការប្រជុំនានា ។
- រៀបចំគំរោងថវិការបស់រដ្ឋាករ តាមការផ្តល់សិទ្ធិរបស់អភិបាលខេត្ត ក្រុង និង ជាអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់រដ្ឋាករ ។
- តាមដានសកម្មភាពរបស់រដ្ឋាករប្រចាំថ្ងៃ និង រាយការណ៍អំពីសកម្មភាពនេះជូនអភិបាលខេត្ត ក្រុង ។

## ជំពូកទី ៣

## របបហិរញ្ញវត្ថុនៃរដ្ឋាករបស់ខេត្ត ក្រុង

មាត្រា ៧ .- ដីការរបស់អភិបាលខេត្ត-ក្រុង ស្តីពីការបង្កើតរដ្ឋាករ ត្រូវកំណត់នូវចំនួនទឹកប្រាក់ដែលខេត្ត ក្រុង ត្រូវផ្តល់នូវទាយជ្ជទានដំបូងសំរាប់ការរៀបចំរដ្ឋាករ ។ ទាយជ្ជទាននេះ អាចបង្កើនឡើង ឬ បន្ថយចុះតំរូវការរបស់សេវាដោយដីការបស់អភិបាលខេត្ត ក្រុង បន្ទាប់ពីមានយោបល់ឯកភាពរបស់គណៈកម្មាធិការ ។

ការបង្កើនទាយជ្ជទាន គឺជាការបើកឥណទាននៅក្នុងថវិការបស់ខេត្ត ក្រុង ហើយការបន្ថយទាយជ្ជទាន គឺជាការបង់ចំណូលដោយរដ្ឋាករក្នុងថវិការបស់ខេត្ត ក្រុង ។

មាត្រា ៨ ._ គំរោងចំណូល និង ចំណាយថវិកាប្រចាំឆ្នាំរបស់រដ្ឋាករ ត្រូវរៀបចំដោយអភិបាលនៃរដ្ឋាករ តាមយោបល់របស់គណៈកម្មាធិការអាជីវកម្ម និង សំរេចដោយអភិបាលខេត្ត ក្រុង ។ អភិបាលខេត្ត ក្រុង ត្រូវបញ្ជូនគំរោងថវិកានេះ ទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការពិនិត្យសំរេច ស្របពេលជាមួយគ្នានឹងគំរោងថវិការបស់ខេត្ត ក្រុង និង ចំលងមួយច្បាប់ទៅក្រសួងមហាផ្ទៃ ។

ពេលវេលានៃការរៀបចំគំរោងថវិការបស់រដ្ឋាករ ដូចគ្នានឹងពេលវេលានៃការរៀបចំគំរោងថវិការបស់ខេត្ត ក្រុងដែរ ។

ថវិការបស់រដ្ឋាករ ត្រូវបានកែសំរួលនៅក្នុងឆ្នាំកំពុងអនុវត្ត និងត្រូវបានទូទាត់នៅដំណាច់ឆ្នាំដូចថវិការបស់ខេត្ត ក្រុងដែរ ។

មាត្រា ៩ ._ ថវិការបស់រដ្ឋាករ ត្រូវបង្ហាញនូវវចនាសម្ព័ន្ធបំពេញ ដែលចែកជាពីរផ្នែកដូចខាងក្រោម ៖

ផ្នែកទី១ ៖ ចំណូល និង ចំណាយអាជីវកម្ម

ចំណូល ៖

- ផលនៃអាជីវកម្ម
- ការកាត់ទុកមុនលើមូលនិធិបំរុង
- ផលផ្សេងៗ និង មិនបានគ្រោងទុក

ចំណាយ ៖

- សោហ៊ុយអាជីវកម្ម និង ថែទាំ
- ប្រាក់បៀវត្ស និង ប្រាក់បំណាច់បុគ្គលិករបស់រដ្ឋាករផ្ទាល់
- ប្រាក់ឈ្នួល និង សោហ៊ុយបន្ទាប់បន្សំនៃចលនវត្ថុ ដែលបានប្រគល់អោយរដ្ឋាករ ។
- ពន្ធ និង អាករគ្រប់ប្រភេទដែលរដ្ឋាករត្រូវបង់
- ចំណាយផ្សេងៗ ។

ផ្នែកទី២ ៖ ចំណូល និង ចំណាយនៃការអភិវឌ្ឍន៍

ចំណូល ៖

- ទាយជ្ជទាននៃការរៀបចំដំបង
- ការកាត់ទុកមុនលើមូលនិធិបំរុង
- ធនធានផ្សេងៗទៀតសំរាប់ការវិនិយោគ ។

ចំណាយ ៖

- ចំណាយសំរាប់ការអភិវឌ្ឍន៍ឋបនកម្ម

+ ការសាងសង់

+ សំភារៈបរិក្ខា

- ការបង្កើនមូលនិធិចល័ត ។

មាត្រា ១០ ._ អតិរេកសុទ្ធទាំងនេះនៃចំណូល លើចំណាយនៃផ្នែកទី ១ របស់រដ្ឋាករដែលមាននៅចុងបញ្ចប់នៃការគ្រប់គ្រងនិមួយៗ ត្រូវផ្ទេរទៅគណនីមួយមានឈ្មោះថា " មូលនិធិបំរុង " ដែលបើកនៅក្នុងលេខនានៃរតនាគារខេត្ត ក្រុង ។

មូលនិធិបំរុងអាចប្រើប្រាស់បាន ដូចជាត្រូវបង្កើតមូលនិធិចល័តរបស់រដ្ឋាករ ឬ ត្រូវធ្វើហិរញ្ញប្បទានសំរាប់ការអភិវឌ្ឍន៍ផ្នែកទី ២ របស់រដ្ឋាករ ។ ចំនួនប្រាក់ដែលនៅសល់មិនប្រើប្រាស់នៃមូលនិធិបំរុង អាចផ្ទេរទៅជាចំណូលថវិការបស់ខេត្ត ក្រុង ។

មាត្រា ១១ ._ មុខងារនៃភ្នាក់ងារគណនេយ្យរបស់រដ្ឋាករ ត្រូវបានរ៉ាប់រងដោយភ្នាក់ងាររតនាគារខេត្ត ក្រុង ម្នាក់ដែលចាត់តាំងឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ១២ ._ គណនីហិរញ្ញវត្ថុរបស់រដ្ឋាករ ត្រូវរៀបចំឡើងដោយភ្នាក់ងារគណនីរបស់រដ្ឋាករ និង ត្រូវចុះទិដ្ឋាការដោយអភិបាលរដ្ឋាករ ដើម្បីអោយស៊ីសង្វាក់គ្នាជាមួយនឹងគណនីរដ្ឋបាល ដែលត្រូវបានពិនិត្យដោយគណៈកម្មាធិការអាជីវកម្ម និង ត្រូវយល់ព្រមដោយអភិបាលខេត្ត ក្រុង ។

ឯកសារនេះ ត្រូវឆ្លុះអោយឃើញជាអាទិ៍នូវស្ថានភាពគណនី " ទាយជ្ជទាននៃការរៀបចំដំបូង " ។

មាត្រា ១៣ ._ នៅពេលណាពិនិត្យឃើញថា អាជីវកម្មរបស់រដ្ឋាករមានឱនភាពនោះ អភិបាលខេត្ត ក្រុង ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីចាត់វិធានការចាំបាច់ សំរាប់ធ្វើអោយមានតុល្យភាពឡើងវិញ ។

ករណីនៅតែមានឱនភាពតទៅទៀតនោះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចសំរេចដកហូតការអនុញ្ញាតធ្វើអាជីវកម្មនៃរដ្ឋាករ និង អោយប្រើរូបភាពគ្រប់គ្រងមួយទៀត បន្ទាប់ពីមានការឯកភាពពីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤

## ការរំលាយរបស់រដ្ឋាករខេត្ត ក្រុង

មាត្រា ១៤ ._ ការធ្វើអាជីវកម្មរបស់រដ្ឋាករខេត្ត ក្រុង ត្រូវបញ្ចប់ដោយការដកហូតការអនុញ្ញាត តាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា ១៥ ._ ប្រកាសស្តីពីការដកហូតការអនុញ្ញាត ត្រូវកំណត់កាលបរិច្ឆេទ ដែលត្រូវបញ្ចប់កិច្ចប្រតិបត្តិការរបស់រដ្ឋាករ ។ គណនីហិរញ្ញវត្ថុដែលមានចែងដូចមាត្រា ១២ ខាងលើ ក៏ត្រូវបញ្ចប់ក្នុងកាលបរិច្ឆេទនោះដែរ ។

មាត្រា ១៦ ._ អភិបាលខេត្ត ក្រុង ត្រូវទទួលបន្ទុកជាអ្នកជំរះបញ្ជី រៀបចំនីតិវិធីក្នុងកិច្ចប្រតិបត្តិការជំរះបញ្ជី ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន ។

លទ្ធផលជំរះបញ្ជី ត្រូវកត់ត្រាក្នុងគណនីមួយ ដែលត្រូវបើកនៅក្នុងលេខនារបស់រតនាគារខេត្ត ក្រុង ក្នុងករណីដែលទ្រព្យសកម្មរបស់រដ្ឋាករ មានមិនគ្រប់គ្រាន់សំរាប់ជំរះបញ្ជីនោះ គឺត្រូវយកថវិការបស់ខេត្ត ក្រុង ធ្វើការទូទាត់ជំនួស ។

មាត្រា ១៧ ._ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលគ្រប់ខេត្ត ក្រុង ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**មាត្រា ១៨ .**_ បទបញ្ញត្តិទាំងឡាយពាក់ព័ន្ធទៅនឹងរបបរដ្ឋបាល ហិរញ្ញវត្ថុ និង ការប្រព្រឹត្តិទៅនៃរដ្ឋាកររបស់ខេត្ត ក្រុង ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបសម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

★★★

**អនុក្រឹត្យលេខ ៣១ អនក្រ.បក**

**ស្តីពីការផ្ទេរឥណទាន**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នរ/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩

- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

**មាត្រា ១ .**_ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤.០០០ លានរៀល ( បួនពាន់លានរៀល ) ពី ជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ក្រសួងអប់រំយុវជន និងកីឡា ផ្នែក អប់រំ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

**មាត្រា ២ .**_ ឥណទានថវិកាក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់បោះពុម្ពសៀវភៅសិក្សា និងប័ណ្ណផ្សេងៗ បំរើសកម្មភាពការងារអប់រំក្រៅប្រព័ន្ធ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែមេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ៣២ អនក្រ.បក

## ស្តីពីការបង្កើតស្ថានអគ្គកុងស៊ុល

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**មាត្រា ១ .**_ បង្កើតស្ថានអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងសៀងហៃ នៃសាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា ២ .**_ ស្ថានអគ្គកុងស៊ុលនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មកុងស៊ុលម្នាក់ ដែលមានឋានៈជាអគ្គកុងស៊ុល ។

**មាត្រា ៣ .**_ សមាសភាពមន្ត្រីកុងស៊ុលផ្សេងៗទៀត យ៉ាងច្រើនបំផុត ០២ នាក់ នឹងត្រូវកំណត់តាមលក្ខការណ៍កុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនកុងស៊ុលទាំងឡាយ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៤ .**_ ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រី និង បុគ្គលិក នៃស្ថានអគ្គកុងស៊ុលនេះ នឹងស្ថិតក្នុងក្របខណ្ឌ " ខ " ។

**មាត្រា ៥ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែមេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## អនុក្រឹត្យលេខ ៣៣ អនក្រ.បក

## ស្តីពីការបង្កើតស្ថានអគ្គកុងស៊ុល

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ .- បង្កើតស្ថានអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ២ .- ស្ថានអគ្គកុងស៊ុលនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មកុងស៊ុលម្នាក់ ដែលមានឋានៈជាអគ្គកុងស៊ុល ។

មាត្រា ៣ .- សមាសភាពមន្ត្រីកុងស៊ុលផ្សេងៗទៀត យ៉ាងច្រើនបំផុត ០២ នាក់ នឹងត្រូវកំណត់តាមលក្ខការណ៍កុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនកុងស៊ុលទាំងឡាយ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ៤ .- ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រី និង បុគ្គលិក នៃស្ថានអគ្គកុងស៊ុលនេះ នឹងស្ថិតក្នុងក្របខ័ណ្ឌ “ ខ ” ។

មាត្រា ៥ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែមេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១០០ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី

**សំរេច**

មាត្រា ១ ._ តែងតាំងជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ០២ រូប មានឋានៈស្មើនឹងប្រធាននាយកដ្ឋាន ដែលមានឈ្មោះ ដូចខាងក្រោម ៖

១- លោក **ឈោ ម៉េងហួរ** ទទួលបន្ទុកផ្នែកបូកសរុប

២- លោក **សុខ សារ៉ន** ទទួលបន្ទុកផ្នែកហេដ្ឋារចនាសម្ព័ន្ធ

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់គ្រងក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១០១ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

មាត្រា ១ ._ តែងតាំងមន្ត្រី ចំនួន ៣៣ រូប ជាជំនួយការឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និង ជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ដែលមានរាយនាមដូចខាងក្រោម ៖

១- លោក **ម៉ិនយ៉ើ ណារិន**

២- លោក ម៉ី ផល្គុណ

៣- លោក ច័ន្ទ មនោ

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់គ្រងក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១០២ អនក្រ.តត

## ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលអាជ្ញាធរ អប្សរា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសំរួលរចនា សម្ព័ន្ធ អាជ្ញាធរអប្សរា
- តាមសំណើរបស់អាជ្ញាធរ អប្សរា

## សំរេច

មាត្រា ១ ._ អនុលោមតាមមាត្រា ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ១៩៩៩ សមាសភាពនៃក្រុមប្រឹក្សាភិបាលអាជ្ញាធរអប្សរា ត្រូវកំណត់ដូចខាងក្រោម :

១- ឯកឧត្តម **វណ្ណ មូលីវណ្ណ** ទីប្រឹក្សារាជរដ្ឋាភិបាលផ្នែកការងារអប្សរា ប្រធានអគ្គនាយក

២- ឯកឧត្តម **ហេង ទត្យប៊ុនឆាត** តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៣- ឯកឧត្តម **អ៊ុត ឈន** តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤- ឯកឧត្តម **អភិបាល ខេត្តសៀមរាប** សមាជិកស្វ័យប្រវត្តិ

៥- ឯកឧត្តម **មីសែល ត្រាណេ** តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៦- ឯកឧត្តម ប្រាជ្ញ ចន្ទ័ តំណាងក្រសួងមហាផ្ទៃ សមាជិក

៧- ឯកឧត្តម ព្រហ្ម សិទ្ធត្ថា តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សមាជិក

៨- ឯកឧត្តម ទឹក គ្រឿនទុត្ថា តំណាងក្រសួងបរិស្ថាន សមាជិក

៩- ឯកឧត្តម ឈិន គង់ហ៊ាន តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១០- ឯកឧត្តម សុ ម៉ារ៉ា តំណាងក្រសួងទេសចរណ៍ សមាជិក

១១- ឯកឧត្តម ទាំង ជុលាន តំណាងបុគ្គលិកអាជ្ញាធរអប្សរា សមាជិក

មាត្រា ២ .- សមាសភាពខាងលើនេះ មានអណត្តិ ៣ ឆ្នាំ ចាប់ពីថ្ងៃអនុក្រឹត្យនេះ ចូលជាធរមាន ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីសាធារណការ និង ដឹកជញ្ជូន អភិបាលខេត្តសៀមរាប ប្រធានអគ្គនាយកអាជ្ញាធរអប្សរា គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១០៣ អនក្រ.តត

## ស្តីពីការផ្ទេរភារកិច្ចរបស់មន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែល ប្រកាសប្រើច្បាប់ស្តីពីការ សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមចំណារឯកឧត្តមឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .**_ ត្រូវបានផ្ទេរភារកិច្ចលោក **ស៊ុយ សេរិទ្ធ** អតីត ជំនួយការសម្ដេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល ទៅបំរើការងារនៅក្រោមឱវាទក្រសួងមហាផ្ទៃ ។

**មាត្រា ២ .**_ បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់គ្រងក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ **ពីថ្ងៃចុះហត្ថលេខាតទៅ ។**

**រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ១០៤ អនក្រ.តត**

**ស្ដីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្ដាល

**សំរេច**

**មាត្រា ១ .**_ ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **យ៉ែម កុសល** នាយកក្រុមហ៊ុនកុសលអាហ័រណា នីហ័រណ សំណង់និងអភិវឌ្ឍន៍ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចំនួន ១២៨.៤២០ ដុល្លារអាមេរិក សំរាប់ជួយកសាងផ្លូវថ្នល់ចម្ងាយ ១០ គីឡូម៉ែត្រ និងអាគារសិក្សា ០២ ខ្នង នៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត កណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយបានសម្រេចតាមស្មារតី ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ១០៥ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ ._ តែងតាំងលោក នួច តែម៉ារី បច្ចុប្បន្នអនុប្រធាននាយកដ្ឋានពិធីការ នៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម ជំនួសលោក សំ ផេន ដែលត្រូវចូលនិវត្តន៍ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១០៦ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

### សំរេច

**មាត្រា ១ .** ផ្លាស់លោក សំ ផេន បច្ចុប្បន្នទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម អោយចូលក្នុងប្រទេស ដោយត្រូវចូលនិវត្តន៍ ។

**មាត្រា ២ .** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១០៧ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សម្រេច**

**មាត្រា ១ .-** ផ្លាស់លោក អ៊ិន ម៉ីយ ពេញប្បន្ន ទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំរាជាណាចក្រថៃឡង់ អោយទៅបំពេញមុខងារជាទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការអនុរដ្ឋលេខាធិការជ្ញានមុខងារសភាធារណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

បាន្តលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១០៨ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សម្រេច**

**មាត្រា ១ .-** តែងតាំងលោក សូ ណារ៉ូ ជាទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌូណេស៊ី ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ១០៩ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**សំរេច**

**មាត្រា ១ ._** តែងតាំងលោក **គង់ សេង** ជាទីប្រឹក្សាផ្ទាល់របស់ឯកឧត្តម **សូ ឃុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានឋានៈស្មើនឹងប្រធាននាយកដ្ឋាន ។

**មាត្រា ៣ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ១១០អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- **បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី**
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ .-** តែងតាំងលោក **នុប ស៊ីសាវជា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានរដ្ឋបាល នៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងសៀងហៃ នៃសាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យលេខ ១១១ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

មាត្រា ១ ._ តែងតាំងលោក ឆុង ឌីន បច្ចុប្បន្នកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងហុងកុងជាអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

★★★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែមេសា ឆ្នាំ១៩៩៩

**សេចក្តីសំរេចលេខ ៣៣ សសរ**

**ស្តីពីការបង្កើតគណៈកម្មការទទួលខុស និងដឹកជញ្ជូនសំណល់ប្លាស្ទិកចំនួន ៦៥០ តោន ចេញពីព្រះរាជាណាចក្រកម្ពុជា**

***

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- យោងអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន

## សំរេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការវេចខ្ចប់ និងដឹកជញ្ជូនសំណល់ពុលស៊ីចចំនួន ២៨០ តោន ចេញពីព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាព :

| | | |
|---|---|---|
| ១- ឯកឧត្តម ទាន់ សាដាន់ | រដ្ឋលេខាធិការក្រសួងបរិស្ថាន | ប្រធាន |
| ២- លោក ខេង សុខុម | អនុប្រធាននាយកដ្ឋានកាកុងត្រូល | អនុប្រធាន |
| ៣- លោក ឡាយ ឫទ្ធី | នាយករង ទីចាត់ការគយ និងរដ្ឋាករ | សមាជិក |
| ៤- លោក លូ គឹមឈុន | ប្រធានកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ | សមាជិក |
| ៥- លោក ភាំង សាខនន្ទ័ | អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

- ទទួលខុសត្រូវតាមដាន ត្រួតពិនិត្យនូវរាល់សកម្មភាពវេចខ្ចប់ឡើងវិញ និងការដឹកជញ្ជូនសំណល់ ចេញពីព្រះរាជាណាចក្រកម្ពុជា របស់ភាគីក្នុង ។
- ទទួលខុសត្រូវសំរបសំរួលរៀបចំសំណុំបែបបទ និងអាជ្ញាប័ណ្ណនាំចេញជូនដល់ភាគីក្នុង ។

ប្រការ ៣ : អភិបាលក្រុងព្រះសីហនុ ត្រូវសហការ និងសំរបសំរួលជាមួយគណៈកម្មការនេះបំពេញភារកិច្ចអោយបានល្អ និងប្រកបដោយសុវត្ថិភាព ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អភិបាលក្រុងព្រះសីហនុ កំពង់ផែក្រុងព្រះសីហនុព្រមទាំង សាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ស ខេង

***

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៣៤ សសរ
## ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យវាយតម្លៃកិត្តិ
## សញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និងកីឡា
- **យោងសេចក្តីសម្រេចលេខ ៦៣ សសរ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មាធិការពិនិត្យវាយតម្លៃភីតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា**
- **តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**សម្រេច**

**ប្រការ ១ : បង្កើតគណៈកម្មធិការចំរុះដែលមានឈ្មោះ " គណៈកម្មាធិការពិនិត្យវាយតម្លៃភីតសញ្ញាប័ត្រ និង លិខិតបញ្ជាក់ការសិក្សា " ដែលមានសមាសភាពដូចមានខាងក្រោម :**

| | |
|---|---|
| **១- ឯកឧត្តម ថ្នាក់ដឹកនាំ ក្រសួងអប់រំ យុវជន និងកីឡា ទទួលបន្ទុកការងារឧត្តមសិក្សា** | **ប្រធាន** |
| **២- ឯកឧត្តម អគ្គនាយកឧត្តមសិក្សាបច្ចេកទេស និងវិជ្ជាជីវៈ** | **អនុប្រធាន** |
| **៣- ឯកឧត្តម អគ្គនាយក អប់រំ** | សមាជិក |
| **៤- លោក តំណាងទីស្តីការគណៈរដ្ឋមន្ត្រី** | សមាជិក |
| **៥- លោក តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ** | សមាជិក |
| **៦- លោក តំណាងក្រសួងសុខាភិបាល** | សមាជិក |
| **៧- លោក ប្រធាននាយកដ្ឋានឧត្តមសិក្សា** | សមាជិក |
| **៨- លោក ប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** | សមាជិក |

**ប្រការ ២ :** គណៈកម្មាធិការនេះមានភារកិច្ច វាយតម្លៃភីតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សាក្នុង និងក្រៅ ប្រទេស តាមសំណើសុំវាយតម្លៃពីបណ្តាស្ថាប័ននានាទូទាំងប្រទេស ។

- កសាងលក្ខណៈវិនិច្ឆ័យសំរាប់វាយតម្លៃភីតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា ក្នុង និង ក្រៅប្រទេស ។

**ប្រការ ៣ :** គណៈកម្មាធិការមានទីស្នាក់ការក្នុងក្រសួងអប់រំ យុវជន និងកីឡា និងមានសិទ្ធិប្រើប្រាស់ត្រា ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីសំរួលការងារ ។

**ប្រការ ៤ :** សមាជិកគណៈកម្មាធិការ ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងពេលប្រជុំវាយតម្លៃភីតសញ្ញាប័ត្រ និងលិខិតបញ្ជាក់ការសិក្សា ក្រសួង ឬ ស្ថាប័នដែលមានការពាក់ព័ន្ធ អាចចាត់តំណាងមកជួយយោបល់ និង ផ្តល់ព័ត៌មានដែលចាំបាច់បន្ថែម ជូនគណៈកម្មាធិការ ។

**ប្រការ ៥ :** គណៈកម្មាធិការ មានសិទ្ធិបង្កើតក្រុមជំនួយការមួយក្រុម ដើម្បីធ្វើជាលេខាធិការ ។

**ប្រការ ៦ :** សេចក្តីសម្រេចលេខ ៦៣ សសរ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ១៩៩៥ របស់គណៈរដ្ឋមន្ត្រី និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងបទបញ្ញត្តិនៃសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម

អស់លោក ជាគណៈកម្មាធិការដូចក្នុងប្រការ ១ មានភារកិច្ច អនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៣៥ សសរ

## ស្តីពីការបង្កើតគណៈកម្មការរៀបចំពិធីសម្ពោធ និង ដាក់អោយដំណើរការជាផ្លូវការខេត្តឧត្តរមានជ័យ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៥/០៧ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតខេត្តឧត្តរមានជ័យ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មាធិការមួយមានឈ្មោះថា គណៈកម្មការរៀបចំពិធីសម្ពោធ និង ដាក់អោយដំណើរការជាផ្លូវការ ខេត្តឧត្តរមានជ័យ ដែលរួមមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | ប្រាំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២-ឯកឧត្តម | ចាយ សាំងយុន | រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាអនុប្រធាន |
| ៣-ឯកឧត្តម | ពេជ ម៉ិនចិន | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ជាសមាជិក |
| ៤-លោក | ម៉ិន សម | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥-ឯកឧត្តម | ប្រាជ្ញ ចន្ទ | អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៦-ឯកឧត្តម | តេង សាវង្ស | អគ្គនាយករង អគ្គនាយកដ្ឋាននគរបាលជាតិ | ជាសមាជិក |

៧-ឯកឧត្ដម ទំនិន ជាតិ អភិបាលខេត្តឧត្ដរមានជ័យ ជាសមាជិក

៨-លោក ម៉ៅ និម អភិបាលរងទី១ ខេត្តឧត្ដរមានជ័យ ជាសមាជិកអចិន្ត្រៃយ៍

៩-លោក ឈាំ នុំ អភិបាលរងទី១ ខេត្តសៀមរាប ជាសមាជិក

១០-លោក អន ស៊ឹ អភិបាលរងទី១ ខេត្តបន្ទាយមានជ័យ ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ច :

- សហការជាមួយក្រសួងស្ថាប័ន អាជ្ញាធរខេត្តពាក់ព័ន្ធ ដើម្បីរៀបចំពិធីសម្ពោធ ប្រកាសជាផ្លូវការ ខេត្តឧត្ដរមានជ័យឲ្យបានក្នុងអំឡុង ខែ មេសា ឆ្នាំ១៩៩៩ នេះ ។
- សហការជាមួយអាជ្ញាធរ ខេត្តឧត្ដរមានជ័យ រៀបចំទីតាំងសាលាខេត្ត សាលាស្រុក សាលាឃុំ និង មូលដ្ឋានសំភារៈចាំបាច់សំរាប់បំពេញការងារ ។
- សហការជាមួយក្រសួងស្ថាប័ន និង ខេត្តពាក់ព័ន្ធ ផ្ទេរភូមិសាស្ត្រ ចលនទ្រព្យ អចលនទ្រព្យ មន្ត្រីរាជការស៊ីវិល យោធា នគរបាល ឲ្យមកចំណុះខេត្តឧត្ដរមានជ័យ ។

ប្រការ ៣ : គណៈកម្មការរៀបចំពិធីសម្ពោធប្រកាសជាផ្លូវការ ខេត្តឧត្ដរមានជ័យមានសិទ្ធិបង្កើតអនុគណៈកម្មការផ្សេងៗ ទៀតសំរាប់ជំនួយការងារ តាមការចាំបាច់ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការប្រធានអង្គភាពសាធារណៈគ្រប់ក្រសួង ស្ថាប័ន និង ខេត្តពាក់ព័ន្ធ និង ឯកឧត្ដមដែលមានឈ្មោះក្នុងប្រការ ១ ខាងលើ មានភារកិច្ចអនុវត្តសេចក្ដីសំរេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

***

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមេសា ឆ្នាំ ១៩៩៩

## សេចក្ដីសំរេចលេខ ៣៦ សសរ

## ស្ដីពីការបង្កើតគណៈកម្មការ សំរាប់ដោះស្រាយ ជម្លោះ បញ្ហាដីធ្លី នៅខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

- លើកកំពស់ការងារចាំបាច់ និង បន្ទាន់របស់រាជរដ្ឋាភិបាល

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការសំរាប់ដោះស្រាយបាតុភាព បញ្ហាដីធ្លី នៅតាមបណ្តាខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ម៉ុល ឈឹង អគ្គាធិការរងទី១ រដ្ឋបាល និងនគរបាលក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម យ៉ាឡេង ឃាត់ ទីប្រឹក្សាឯកឧត្តមទេសរដ្ឋមន្ត្រី សុខ អាន ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៣-ឯកឧត្តម ឧត្តមសេនីយ៍ទោ សិទ្ធ ឌី មេបញ្ជាការរងកងទ័ពជើងគោក អនុប្រធាន

៤-ឯកឧត្តម ឧត្តមសេនីយ៍ទោ ខឹម សុផាត ប្រធានខុទ្ទកាល័យអគ្គមេបញ្ជាការ ក.ប.ខ.ភ.ម សមាជិក

៥-ឯកឧត្តម សក់ សេដ្ឋា អគ្គនាយករដ្ឋបាលក្រសួងមហាផ្ទៃ សមាជិក

៦-ឯកឧត្តម នុល ចរះ ប្រធានអធិការកិច្ចរដ្ឋបាល សមាជិក

៧-ឯកឧត្តមអភិបាលខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្ត តាកែវ សមាជិក

៨-អភិបាលស្រុកពាក់ព័ន្ធ សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច :

- ចុះស្រាវជ្រាវ និង លើកវិធានការដោះស្រាយអោយមានប្រសិទ្ធភាព នូវរាល់បាតុភាពដែលកើតឡើងតាមបណ្តាខេត្តទាំងបី ។
- ធ្វើរបាយការណ៍ អំពីការដោះស្រាយ និងលទ្ធផលនៃការងារខាងលើជូនរាជរដ្ឋាភិបាល ។

ប្រការ ៣ : សមាជិកនៃគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ សំរាប់សំរួលការងារ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកំពង់ចាម ខេត្ត តាកែវ ខេត្តកំពង់ស្ពឺ និងឯកឧត្តម អស់លោកដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុក អនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

★★★

រាជធានីភ្នំពេញ ,ថ្ងៃទី១២ ខែមេសា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ៣៧ សសរ
## ស្តីពីការបង្កើតគណៈកម្មការដោះស្រាយ
## ទីតាំង និង ជួសជុលប៉ូវីកីឡា

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** ប្រគល់ភារកិច្ច ដើម្បីដោះស្រាយទីតាំង និង ជួសជុលប៉ូវីកីឡាដល់គណៈកម្មការ ដែលមាន សមាសភាពដូចខាងក្រោម :

១-ឯកឧត្តម **អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ប្រធាន

២-ឯកឧត្តម **ហុក ឡុងឌី** អគ្គនាយកនគរបាលជាតិ អនុប្រធាន

៣-ឯកឧត្តម **ទី សាម៉ឺឌី** អនុប្រធានទី១ នៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អនុប្រធាន

៤-ឯកឧត្តម **ប៉ុក ថន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា អនុប្រធាន

៥-ឯកឧត្តម **ឌុំ សារិន** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូនិយកម្ម និងសំណង់ សមាជិកអចិន្ត្រៃយ៍

៦-លោកជំទាវ **ស៊ិន ស៊ី** អគ្គលេខាធិការរងរាជរដ្ឋាភិបាល អគ្គលេខាធិការ

៧-ឯកឧត្តម **ខី តាឃី** អនុរដ្ឋលេខាធិការក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៨-ឯកឧត្តម **ម៉ម សុផាណា** អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ សមាជិក

៩-ឯកឧត្តម **លី យ៉ុមីន** អនុរដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១០-ឯកឧត្តម **ចេវ គឹមហេង** អភិបាលរងរាជធានីភ្នំពេញ សមាជិក

១១-លោក **មាស សារិន** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សមាជិក

១២-លោក **ណុប ស៊ីណូ** ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់ សមាជិក

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ចដោះស្រាយការងារដូចខាងក្រោមនេះ :

- ដោះស្រាយទីតាំងបរិវេណបូរីកីឡា សំរាប់ធ្វើការជួសជុលក្នុងក្របខ័ណ្ឌ ជំនួយឧបត្ថម្ភរបស់ភាគីសាធារណរដ្ឋប្រជាមានិតចិន ។
- លើកវិធានការដោះស្រាយ លើកប្រជាពលរដ្ឋដែលស្នាក់នៅក្នុងបរិវេណបូរីកីឡាឲ្យចាកចេញពីទីតាំងបូរីកីឡាទាំងមូល ដោយស្រាវជ្រាវស្រង់ស្ថិតិពិតប្រាកដតាមប្រភេទអ្នកដែលរស់នៅក្នុងបរិវេណបូរីកីឡាតាមដំណាក់កាលពេលវេលាដែលបានស្នាក់នៅ ដោយដោះស្រាយបញ្ហាសំណង់អនាធិបតេយ្យក្នុងបរិវេណបូរីកីឡាព្រមទាំងដោះស្រាយលើកទីតាំងដែលផ្តល់អោយទូរទស្សន៍ប៉ុស្តិ៍លេខ៥ និងកំណត់ប្រភេទនៃការដោះស្រាយប្រាក់ឧបត្ថម្ភ ។
- ធ្វើជាដៃគូរពិភាក្សាជាមួយភាគីចិន ដើម្បីកសាងភូមិ និងកសាងសង់លំនៅដ្ឋានសំរាប់ឲ្យប្រជាពលរដ្ឋ ដែលផ្ទេរពីបូរីកីឡាទៅស្នាក់នៅ ។
- ដោះស្រាយផ្ទះសំបែង និង ប្រាក់ឧបត្ថម្ភជូនគ្រួសារប្រជាពលរដ្ឋដែលត្រូវផ្លាស់ទីលំនៅចេញពីបូរីកីឡា
- ចូលរួមក្នុងការដេញថ្លៃសំណង់ ដែលមកជួសជុលនិងកសាងសង់បូរីកីឡា ។
- ត្រួតពិនិត្យគុណភាព និង ដំណើរការជួសជុលបូរីកីឡា ។
- ពិភាក្សាសំរបសំរួលឥណទាន ប្រើប្រាស់ក្នុងការជួសជុលបូរីកីឡា និង ជ្រើសរើសសហគ្រិនសំណង់ដែលមានស្នាដៃក្នុងការសាងសង់ជួសជុលបូរីកីឡា ជាមួយភាគីសាធារណរដ្ឋប្រជាមានិតចិន
- ធ្វើរបាយការណ៍សរុបអំពីលទ្ធផលការងាររបស់គណៈកម្មការជូនរាជរដ្ឋាភិបាល

**ប្រការ ៣ :** គណៈកម្មការនេះ មានសិទ្ធបង្កើតអនុគណៈកម្មការឬ ក្រុមការងារមួយចំនួន ដើម្បីជាជំនួយការ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**ប្រការ ៤ :** សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥ :** រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាការធិការជាតិអូឡាំពិក ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវអស់លោកដែលមានឈ្មោះ ក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីសំរេច ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមេសា ឆ្នាំ ១៩៩៩

## ៣-សារាចរណែនាំ

### សារាចរណែនាំលេខ ០៦ សរ.ណន

### ស្តីពីការធានានិរន្តរភាព សកម្មភាព អាជីវកម្ម នីហរណ៍និងនាំចូលតាមច្រកព្រំដែន ដោយរលូនទាន់ពេលវេលា
(ស្តីពីការធានានិរន្តភាព សកម្មភាព អាហំណេ នីហរណ៍និញ នៅថ្ងៃឈប់សំរាកការងារ)

***

កន្លងមករាជរដ្ឋាភិបាលបានប្តេជ្ញាធ្វើការកែទំរង់សេដ្ឋកិច្ច ដើម្បីជំរុញជាប្រចាំដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ក៏ដូចជាការបង្កលក្ខណៈងាយស្រួលដល់វិនិយោគិន អាជីវករ ពាណិជ្ជករ នាំចូល នាំចេញទាំងឡាយក្នុងការប្រកបអាជីវកម្ម សេវាកម្មរបស់ខ្លួន ។ ដើម្បីធានាបាននូវភាពរស់រវើកនៃសកម្មភាពសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពដែលជាគោលដៅ នៃរាជរដ្ឋាភិបាលសេដ្ឋកិច្ចនោះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់អាជ្ញាធរ និងភ្នាក់ងារមានសមត្ថកិច្ចគ្រប់ប្រភេទដែលមានតួនាទី និង ភារកិច្ចប្រចាំការនៅតាមទីស្នាក់ការត្រួតពិនិត្យនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ ទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាសជាពិសេសកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ ភ្នំពេញ តែស្គូត អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុងនូវវិធានការដូចតទៅ ៖

១-អាជ្ញាធរនិងភ្នាក់ងារមានសមត្ថកិច្ច គ្រប់ប្រភេទ តាមស្ថាប័ន និងតាមច្រកនីមួយៗ ត្រូវចាត់តាំងកម្លាំងប្រចាំការមួយក្នុងកំរិតដែលអាចធានានិរន្តរភាព សកម្មភាពសាររ័ណ នីហរណកម្មនិងនៅរាល់ថ្ងៃឈប់សំរាកជាផ្លូវការនានា ដោយធ្វើការរ៉ះប៉ូវថ្ងៃឈប់សំរាកសងវិញតាមការឯកភាពគ្នានៅមូលដ្ឋាននីមួយៗ ។

២-ត្រូវផ្តួចផ្តើមពង្រឹងផ្សព្វផ្សាយលើកទួលទួលលោក និងទាន់ពេលវេលានូវវិធានការថ្មីនេះ ដល់វិនិយោគិន អាជីវករ ពាណិជ្ជករទាំងឡាយណាបានដឹងពីរឿងនេះ ។

ក្រោយពេលទទួលបានសារាចរណែនាំនេះ ក្រសួង. ស្ថាប័ន អាជ្ញាធរ និង ភ្នាក់ងារមានសមត្ថកិច្ចដែលមានការពាក់ព័ន្ធ នឹងបញ្ហាខាងលើ ត្រូវចាត់ចែងអនុវត្តជាការប្រញាប់ អោយមានប្រសិទ្ធភាពខ្ពស់បំផុត ។

នាយករដ្ឋមន្ត្រី

សម្តេចតេជោ ហ៊ុន សែន

បណ្ឌិតសេនា និងត្រា

ហ៊ុន សែន

***

# III- ការងាររបស់ក្រសួង

## ១-នីតិការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី០២ ខែមេសា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ៤០២ ឧក.ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៥៥៨/៩៩ ក.រ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ២៧៧៨ ធក.ស ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាក្រុងភ្នំពេញ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អលឡាយ ស្មាត ទិចថាយ ខូ អិលធីឌី ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ១៩៩៩

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន អលឡាយ ស្មាត ទិចថាយ ខូអិលធីឌី ( ALLED SMART TEXTILE Co., LTD ) តំណាងដោយលោក NGAN SHUN KWING BEN សញ្ជាតិ CANADA ភេទប្រុស អាយុ ៤៧ ឆ្នាំ អាសយដ្ឋាន 1408 W 55 th Avenue Vancouver, B.C V6P 1R5, CANADA កាន់លិខិតឆ្លងដែនលេខ BC 062707 ចុះថ្ងៃទី28-10-1996 បង្កើត " រោងចក្រចាក់សំលៀកបំពាក់នាំចេញ " ដែលមានឈ្មោះថា " រោងចក្រកាត់ដេរ អលឡាយ ស្មាត ទិចថាយ " មានទីតាំងនៅជាន់ $E_5$, $E_6$ អគារ A នៃប្លង់សាងសង់លេខ ៦២៦ សជ/៩៧ ស្ថិតតាមបណ្តោយផ្លូវពីស្ពានីយវិទ្យុស្ទឹង មានជ័យ ទៅចោមចៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ការសាងសង់ ការរៀបចំគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានសំរេចក្នុងរយៈពេល ០៣ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ " កាត់ សំលៀកបំពាក់ " ទៅតាមគំរូដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវស៊ើវិញ្ញាបនបត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវបើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អលឡាយ ស្មាត ទិចថាយ ខូអិលធីឌី ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអនុភាព គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស៊ុយ សែម

***

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែមេសា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ៤០៣ ឧក.ប្រក

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ១៩២៦/៩៨ ក.វ.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញលិខិតលេខ ៣៤៩៤ សអ.ស ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៨ របស់សាលាក្រុងភ្នំពេញ ស្ដីពីការអនុញ្ញាតឲ្យសាងសង់អាគារផលិតធូបផ្កា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន វែលឌីង លីមីធីត ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ១៩៩៩

**សម្រេច**

ប្រការ ១ : អនុញ្ញាតឲ្យក្រុមហ៊ុន វែលឌីង លីមីធីត ( WELDING CO., LTD ) តំណាងដោយលោក IAN ENKO GUEORGUI សញ្ជាតិ រុស្ស៊ី ភេទប្រុស អាយុ ៥៨ ឆ្នាំ អាសយដ្ឋាន # 23,B1d.2, Bolshaya Bronnaya Street, Moscow RUSSIA កាន់លិខិតឆ្លងដែនលេខ 43N$_0$1750504 ចុះថ្ងៃទី30-5-1995 បង្កើត "រោងចក្រផលិតធូបផ្កា"ដែលមានឈ្មោះថា "រោងចក្រ ធូបផ្កា វែលឌីង" មានទីតាំងនៅស្ថិតផ្លូវវត្តគោកចំបក់ ភូមិត្រពាំងល្វា សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : ការសាងសង់ ការរៀបចំគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ដែលបានតម្កល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានសម្រេចក្នុងរយៈពេល ៦ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ "ធូបផ្កា" ទៅតាមគំរូដែលបានតម្កល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៦ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៧ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន វែលឌីង លីមីធីត ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៨ : ប្រកាសនេះមានអនុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ស៊ុយ សែម**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី០២ ខែមេសា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ៥០៤ ឧក.ប្រក

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេច **នរោត្តមសីហនុ** ព្រះមហាក្សត្រនៃកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៥៦/៩៩ គ.វ.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ២៧៧៨ ធត.ស ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាក្រុងភ្នំពេញ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ខេមបូឌា ហ្វេសិន ខូអិលធីឌី ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូឌា ហ្វេសិន ខូអិលធីឌី ( CAMBODIA FASHIONS Co.,LTD ) តំណាងដោយលោក NGAN SHUN KWING BEN សញ្ជាតិ CANADA ភេទប្រុស អាយុ ៤៧ ឆ្នាំ អាសយដ្ឋាន 1408 W 55 th Avenue Vancouver, B.C V6P IR5, CANADA កាន់លិខិតឆ្លងដែនលេខ BC 062707 ចុះថ្ងៃទី28-10-1996 បង្កើត " រោងចក្រ កាត់ដេរសម្លៀកបំពាក់នាំចេញ " ដែលមានឈ្មោះថា " រោងចក្រកាត់ដេរ ខេមបូឌា ហ្វេសិន " មានទីតាំងនៅជាន់ $E_3$, $E_4$ អគារ A នៃប្លង់សាងសង់លេខ ៦២៦ សជ/៩៧ ស្ថិតតាមបណ្តោយផ្លូវពីស្ពានីយ៍ទៅខ្សឹង មានជ័យទៅចោមចៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ការសាងសង់ ការរៀបចំគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អោយបានសំរេចក្នុងរយៈពេល ០៣ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

**ប្រការ ៣ :** ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ។

**ប្រការ ៤ :** រោងចក្រនេះត្រូវបានអនុញ្ញាតអោយ " កាត់-ដេរ សំលៀកបំពាក់ " ទៅតាមគំរូដែលបានតំកល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៥ :** រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហ-កម្ម រ៉ែ និង ថាមពល ។

**ប្រការ ៦ :** ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ ៧ :** ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៨ :** ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ខេមបូឌា ហ្វេសិន ខូអិលធីឌី ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន ។

**ប្រការ ៩ :** ប្រកាសនេះមានអនុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
បាត់លេខា និងត្រា
**ស៊ុយ សែម**

★★★

ទ្រព្យសម្បត្តិ ពុទ្ធសាសនបណ្ឌិត្យ
បញ្ជី ០០៦.១ ឧត្តម ១និកាយ

បញ្ជី ០៦៣.៨ [illegible]

បោះពុម្ពនៅពេលពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២.៧៥០ រៀល